ការរៀនតាមអនឡាញនឹងបន្តរហូតដល់ថ្ងៃទី១ខែមិនា

ដោយសារតែការកើនឡើងយ៉ាងខ្លាំងនៃករណីវីរុសកូវិឌ-១៩ ក្រសួងអប់រំឡុងប៊ីចនឹងបន្តផ្តល់ការបង្ហាត់បង្រៀនតាមរយៈអនឡាញយ៉ាងឆាប់ណាស់រហូតដល់ថ្ងៃទី១ខែមិនា ជាជាងការចាប់ផ្តើមបង្រៀននៅសាលារៀនវិញនៅថ្ងៃទី២៨ខែមករា ដូចដែលបានសង្ឃឹមទុកនោះ។

តំបន់ផ្សេងៗនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា និងនៅក្នុងស្រុកឡូសអិនជើលែស បានឃើញចំនួនបំបែកឯកត្តកម្មនៃករណីវីរុសកូវិឌ១៩ ជាមួយនឹងចំនួនអ្នកជំងឺព្យាបាលនៅមន្ទីរពេទ្យកើនឡើងដល់កំណត់។ ជាអកុសល ទិន្នន័យសុខភាពក្នុងតំបន់និងរដ្ឋបានទស្សទាយថានឹងមានកំណើនឡើងថែមទៀតនូវករណីវីរុសកូវិឌ១៩ បន្ទាប់ពីរដូវបុណ្យទានខែធ្នូនេះ។ ហេតុដូច្នេះ នៅក្នុងកាលៈទេសៈនេះ ស្រុកឡូសអិនជើលែស ប្រហែលជាមិនអាចបំពេញបានតាមកម្រិត ដើម្បីផ្លាស់ប្តូរទៅក្នុងភាពមានលក្ខខ័ណ្ឌតិច នៅថ្ងៃទី១ខែមករានេះបានទេ។ ជាលទ្ធផល សាលារៀននឹងមិនអាចអនុញ្ញាតឱ្យបើកបង្រៀនវិញនៅក្នុងខែមករាទេ។ បើថ្ងៃគំរោងបើកសាលាវិញនៅថ្ងៃទី១ខែមិនាមិនអនុញ្ញាតឱ្យនៅពេលនោះ ថ្ងៃបើកសាលារៀនវិញនឹងរុញបន្តទៅថ្ងៃទី១២ខែមេសា ដែលជាថ្ងៃបន្ទាប់ពីការសម្រាកនារដូវផ្ការីក។

ក្រសួងអប់រំ LBUSD ជានិយោជកធំជាងគេនៅឡុងប៊ីច ដោយមានសិស្សជាង៧០០០០នាក់និងបុគ្គលិក១២០០០នាក់។ បន្ថែមពីលើកាតព្វកិច្ចរបស់ក្រសួងអប់រំឡុងប៊ីចក្នុងការអនុវត្តតាមលក្ខខ័ណ្ឌរបស់រដ្ឋសម្រាប់ការបើកសាលារៀនវិញ ក្រសួងអប់រំ LBUSD យកចិត្តទុកដាក់លើកាតព្វកិច្ចសហគមន៍ដើម្បី បន្ធូរបន្ទុករបស់មន្ទីរពេទ្យនៅក្នុងតំបន់ និងអ្នកធ្វើការសុខភាពជួរមុខ ខណៈកំពុងបន្ទាបហានិភ័យនូវជំងឺធ្ងន់ធ្ងរសម្រាប់ប្រជាពលរដ្ឋដែលងាយទទួលរងនូវគ្រោះថ្នាក់។

អ្នកដឹកនាំការអប់រំ និងបុគ្គលិក ទទួលស្គាល់នូវបន្ទុកដែលសិស្ស គ្រួសារ និងមិត្តរួមការងារកំពុងប្រឈមមុខ ក្នុងបរិយាការរៀនសូត្រតាមអនឡាញ។ អគារនានារបស់ LBUSD ត្រូវបានរៀបគ្រោងបំពាក់នូវឧបករណ៍និងផែនការសម្រាប់បើកសាលារៀនវិញនៅពេលណាដែលក្រសួងអប់រំត្រូវបានអនុញ្ញាតឱ្យ។ ទន្ទឹមនឹងនេះ រវៀងថ្ងៃទី៤មករានិងទី១មិនា LBUSD នឹង:

- បន្តផ្តល់ការជួយមើលថែកុមារសម្រាប់អ្នកធ្វើការសំខាន់និងក្រុមគ្រួសារចុះឈ្មោះនៅក្នុង Kids' Club, មជ្ឈៈមណ្ឌលបណ្តុះបណ្តាលកុមារ និងហ៊ែឌស្តាត (Child Development Centers & Head Start)
- បន្តធ្វើការស្ទង់ប្រមាណសិស្សសម្រាប់ទទួលសេវាកម្មគាំទ្រផ្សេងៗ
- ចាប់ផ្តើមផ្តល់សេវាកម្មក្នុងសហការណ៍បង្រៀនសហនៅថ្នាក់មុនចូលសាលា
- សហការជាមួយក្រសួងសុខាភបាលក្នុងតំបន់និងដៃគូការងារដើម្បីស្វែងរកមើលឱកាសសម្រាប់នាំសិស្សពីកម្រិតថ្នាក់អន្តរមត្តេយ្យទៅដល់ថ្នាក់ទី២ឱ្យបានចូលរៀននៅសាលាវិញតាមរយៈការស្នើសុំលើកលែង
- បន្តគាំទ្រគ្រូបង្រៀនក្នុងការប្រតិបត្តិនូវការបង្រៀនតាមអនឡាញទៅតាមវិធីដែលប្រសើរបំផុត

ក្រសួងអប់រំឡុងប៊ីចពេញចិត្តនឹងការគាំទ្ររបស់អ្នករាល់គ្នានៅក្នុងពេលដ៏លំបាកនេះហើយរំពឹងដល់ការស្វាគមន៍សិស្សទាំងអស់ឱ្យចូលរៀននៅសាលាវិញឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។